**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង រវាងនាយកក្រុមហ៊ុន ឈុន ឌីង ព្រីនធីង ខូអិលធីឌី ជាមួយប្រធានសហជីព តំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុន

ឆ្នាំពីរពាន់ម្ភៃបី ខែមិថុនា ថ្ងៃទីមួយ វេលាម៉ោងប្រាំបួនគត់ នៅការិយាល័យក្រុមហ៊ុន **ឈុនឌីង ព្រីនធីង ខូអិលធីឌី** មានកិច្ចប្រជុំពិភាក្សា រវាងនាយកក្រុមហ៊ុន ជាមួយប្រធានសហជីព តំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុមប្រចាំក្រុមហ៊ុនស្តីពីការព្យួរកិច្ចសន្យាការងារក្រោយពីបានពិភាក្សាគ្នារួចមក ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោម ៖

១.បច្ចុប្បន្ននៃក្រុមហ៊ុនដែលខ្វះអ្នកបញ្ជាទិញដែលបណ្តាលអោយសង្វាក់ផលិតកម្មត្រូវផ្អាកដំណើរការ។ ហេតុដូចនេះក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ២៦នាក់ (ស្រី១៣នាក់) ក្នុងចំណោមកម្មករនិយោជិតសរុប ៩៩នាក់ (ស្រី៥៣នាក់) រយៈពេល ៣០ថ្ងៃ ដោយគិតចាប់ពី ថ្ងៃទី១២ ខែមិថុនា ឆ្នាំ ២០២៣ រហូតដល់ ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣។

២.ភាគីទាំងពីរយល់ព្រមទទួលយកនិងផ្តល់ប្រាក់ឧបត្ថមចំនួន៤៥ដុល្លាអាមេរិក(បូករួមទាំងប្រាក់ធ្វើដំណើរ និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ) សម្រាប់កម្មករ ម្នាក់ៗ ក្នុងរយៈ ពេលព្យួរការងារនេះ ។

៣.ក្នុងករណីបងប្អូនកម្មករ មិនបានចូលធ្វើការវិញតាមការកំណត់នេះទេ ក្រុមហ៊ុននឹងអនុវត្តតាម ច្បាប់ស្តីពីការងារ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។

ប្រាក់ឧបត្ថមក្នុងកំឡុងពេលព្យួរកិច្ចសន្យានេះនឹងបើកជូនបងប្អូនកម្មករនិយោជិកនៅថ្ងៃទី១០ខែមិថុនា ឆ្នាំ ២០២៣ ។

អង្គប្រជុំបានចប់នៅវេលាម៉ោង០៩ និង៤០នាទី ព្រឹក នាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងរលូន។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែជេស្ឋ ឆ្នាំថោះ ចត្វាស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី 01 ខែ មិថុនា ឆ្នាំ2023

នាយកក្រុមហ៊ុន

ស្នាមមេដៃសហជីព

ឡូញ គុន

ស៊ីថា ប៊ុនថាន់

ស្នាមមេដៃតំណាងកម្មករនិយោជិត

អ៊ិន ដា

សាត់ ផាត់ណា

ព្រះរាជាណាចក្រកម្ពុជា
ឈុន ឌីង ព្រីនធីង ខូ អិលធីឌី
QUN DING PRINTING Co., Ltd.
KINGDOM OF CAMBODIA